# សារលិខិតសម្រាប់ថ្ងៃបុណ្យណូអែល
## នៃមិត្រូប៉ូលីតនៃសិង្ហបុរីនិងភូមិភាគអាស៊ីអាគ្នេយ៍ សេរហ្គី
## ជូនទៅកាន់ពួកប៊ីស្សបជាទីគោរពបំផុត ពួកបូជាចារ្យ ពួកឌីកន
## ពួកសង្ឃ ពួកដូនជី និង គ្រិស្តសាសនិកអរតូដុក្សទាំងអស់
## នៃព្រះសហគមន៍នៃភូមិភាគអាស៊ីអាគ្នេយ៍ (អ៊ែកសាក្រុកាត់ នៃភូមិភាគអាស៊ីអាគ្នេយ៍)

**ពួកប៊ីស្សបជាទីគោរពដ៏ខ្ពង់ខ្ពស់ និងពួកលោកឪពុកជាទីគោរព**
**បងប្អូនប្រុសស្រីជាទីស្រឡាញ់រាប់អានទាំងឡាយ!**

នៅថ្ងៃដ៏ត្រចះត្រចង់នេះ ខ្ញុំសូមសំដែងសេចក្តីអំណរសាទរដល់បងប្អូនទាំងអស់គ្នា ជាមួយពិធីបុណ្យកំណើតខាងសាច់ឈាមរបស់ព្រះគ្រីស្ទ!

ថ្ងៃនេះ មនុស្សម្នាច្រៀងសរសើរព្រះអម្ចាស់ពេញដោយអំណរ ដោយសម្រាប់ជាប្រយោជន៍នៃសេចក្តីសង្គ្រោះរបស់យើង ទ្រង់បានបន្ទាបអង្គទ្រង់ និងបានក្លាយជាមនុស្សម្នាក់ ហើយដោយហេតុនេះអស់អ្នកដែលរង់ចាំការយាងមកដល់របស់ទ្រង់ត្រូវបានរួបរួម ។ ក្នុងពេលបច្ចុប្បន្ននេះ ការរួបរួមគ្នាដ៏ពិតប្រាកដរបស់អ្នកមានជំនឿលើព្រះគ្រីស្ទ គឺមានសារៈសំខាន់ជាពិសេសសម្រាប់យើងម្នាក់ៗ។ ព្រះអម្ចាស់បានទូលសូមព្រះវរបិតារបស់ទ្រង់ជាពិសេសសម្រាប់ការរួបរួមនេះ ហើយភាពពេញលេញនៃសាសនាចក្រក៏អធិស្ឋានសម្រាប់វាយ៉ាងក្លៀវក្លា ហើយនិងដួងចិត្តនៃអស់អ្នកដែលរងទុក្ខពីការបែកបាក់ អ្នកដែលស្រឡាញ់អ្នកជិតខាង និងអ្នកដែលចង់ក្លាយជាអ្នកបង្កើតសន្តិភាព ហើយត្រូវបានគេហៅថាជាកូនប្រុសរបស់ព្រះជាម្ចាស់[1] គឺមានទុក្ខព្រួយ។ វាមិនមែនជារឿងចៃដន្យទេដែលពាក្យថាសន្តិភាពត្រូវបានរកឃើញជាញឹកញាប់នៅក្នុងគម្ពីរដំណឹងល្អ៖ ព្រះអង្គសង្គ្រោះបានបន្សល់ទុកនូវសន្តិភាពរបស់ទ្រង់ដល់ពួកសាវ័ក ទ្រង់បានជួបពួកគេដោយពាក្យថា "សូមឲ្យអ្នកបានប្រកបដោយសន្តិភាព" បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ - ហើយនេះជាហេតុដែល ពរជ័យ នេះ តែងលឺឡើងក្នុងវេនថ្វាយង្គំរបស់យើង។

តើយើងត្រូវការអ្វីខ្លះក្នុងគ្រាលំបាកបច្ចុប្បន្ន តើយើងអាចរួមចំណែកអ្វីខ្លះក្នុងការបង្កើតសន្តិភាព និងការរួបរួម? ទីមួយ វាជារឿងសំខាន់ដែលមិនត្រូវចុះចាញ់នឹងភាពអស់សង្ឃឹម និងរក្សាភាពរឹងមាំនៃសេចក្តីជំនឿ - វាជាគ្រឹះមួយដ៏សំខាន់ ដែលបើសិនគ្មានវាគឺវាមិនអាចទៅរួចនោះទេក្នុងការកសាងជីវិតដែលពោរ

[1] ម៉ាថាយ 5:9

ពេញដោយអត្ថន័យពិត និងសេចក្តីអំណរខាងវិញ្ញាណ។ ទីពីរ ចាំបាច់ត្រូវចេះលះបង់ពេលវេលារបស់អ្នក មិនមែនសម្រាប់ការអាន និងការពិភាក្សាព័ត៌មានដែលមិនចេះចប់ ធ្វើឱ្យស្ថានការណ៍ដែលកាន់តែតានតឹងឡើងនោះទេ ប៉ុន្តែត្រូវទៅមើលព្រះវិហារដ៏វិសុទ្ធនៃព្រះជាម្ចាស់ ហើយមិនបន្ថយនូវការអធិស្ឋាន និងការធ្វើការដោយស្មោះត្រង់នៅតាមកន្លែងបម្រើការ ដែលព្រះអម្ចាស់បានកំណត់អោយយើង។ ទីបី យើងត្រូវអនុវត្តអំពើនៃក្តីមេត្តា ប្រព្រឹត្តចំពោះអ្នកជិតខាងរបស់យើងដោយការអត់ធ្មត់ និងសេចក្តីស្រឡាញ់ លើកទឹកចិត្តដល់អ្នកដែលបាក់ទឹកចិត្ត និងគាំទ្រអ្នកទន់ខ្សោយ បង្ហាញការអាណិតអាសូរ សេចក្តីសប្បុរស និងសេចក្តីទន់ភ្លន់ ហើយ សូមឱ្យព្រះអង្គសង្គ្រោះដែលបានយាងមកក្នុងពិភពលោកនេះបានពង្រឹងដល់យើងនៅក្នុងការណ៍ទាំងនេះ។

ខ្ញុំសូមធ្វើការសំដែងសេចក្តីអំណរសាទរ លោកអ្នកបងប្អូនម្តងហើយម្តងទៀតក្នុងពិធីបុណ្យនៃកំណើតខាងសាច់ឈាមនៃព្រះគ្រីស្ទ ខ្ញុំសូមជូនពរឱ្យអ្នកទាំងអស់គ្នានូវកម្លាំងខាងវិញ្ញាណ និងខាងរាងកាយ សន្តិភាព សេចក្តីអំណរ និងវិបុលភាពហើយនិងជំនួយដ៏សប្បុរសរបស់ព្រះអម្ចាស់ ដែលនៅក្នុងទ្រង់ទាំងពិភពលោកដែលមើលឃើញនិងមើលមិនឃើញ បានមានអំណរខាងឯវិញ្ញាណ។

**មីត្រូប៉ូលីតនៃសិង្ហបុរីនិងភូមិភាគអាស៊ីអាគ្នេយ៍**
**ប្រធាននៃ អ៊ើកសាវ្រកាត់ នៃភូមិភាគអាស៊ីអាគ្នេយ៍**